ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខៈ ០០០៥ រ៉ែ.អ.ប្រក.ប្រក

# ប្រកាស
## ស្តីពី
## លក្ខខណ្ឌនៃអាជ្ញាបណ្ណសន្និធិឧស្ម័នអិល ភី ជី

លេខ ០០០៥ រ៉ែ.អប្រក.ថព ចុះថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០២៣

## រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៧ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរ៉ែនិងថាមពល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧១៩/០០៦ ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងប្រេងកាត និងផលិតផលប្រេងកាត
- បានឃើញអនុក្រឹត្យលេខ ១៣៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរ៉ែនិងថាមពល
- បានឃើញប្រកាសរួមលេខ ១២៨ សហវ.ប្រក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១៧ របស់ក្រសួងរ៉ែនិងថាមពល និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកែសម្រួលតារាងឧបសម្ព័ន្ធភ្ជាប់នឹងប្រកាសរួមលេខ ១៤៥១ សហវ.ប្រក ចុះថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការផ្តល់សេវាសាធារណៈនិងការពិន័យអន្តរការណ៍ជាប្រាក់ ដោយក្រសួងរ៉ែនិងថាមពល
- បានឃើញលិខិតស្នើសុំ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០២២ របស់ក្រុមហ៊ុន ឡែក សូណាល់ ស៊ីវ៉ស
- យោងតាមការចាំបាច់របស់ក្រសួងរ៉ែនិងថាមពល



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

## សម្រេច

**ប្រការ១.-**

ប្រកាសនេះមានគោលបំណងកំណត់អំពីលក្ខខណ្ឌ ក្នុងការផ្តល់អាជ្ញាបណ្ណសន្និធិឧស្ម័នអិល ភី ជី សម្រាប់ក្រុមហ៊ុន **ឡេក សូណាល់ សឺវីស** (LEK SONAL SERVICE Co., Ltd.) ដែលបានចុះបញ្ជីពាណិជ្ជកម្មលេខ ០០០០២០៣០ និងមានទីស្នាក់ការនៅភូមិបន្ទាយចាស់ សង្កាត់ស្លក្រាម ក្រុងសៀមរាប ខេត្តសៀមរាប **"អ្នកទទួលបានអាជ្ញាបណ្ណ"** ធ្វើការសាងសង់និងធ្វើប្រតិបត្តិការ និងថែទាំមណ្ឌលសន្និធិឧស្ម័នអិល ភី ជី ដែលមានទីតាំងស្ថិតនៅភូមិផ្សារកណ្តាល សង្កាត់ផ្សារកណ្តាល ក្រុងប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ។

**ប្រការ២.-**

អ្នកទទួលបានអាជ្ញាបណ្ណត្រូវបានអនុញ្ញាតឱ្យធ្វើសកម្មភាពធុរកិច្ច ដូចមានចែងក្នុងប្រការ១ នៃប្រកាសនេះ (ធុរកិច្ចដែលអនុញ្ញាត)។ ក្នុងករណីអ្នកទទួលបានអាជ្ញាបណ្ណមានបំណងធ្វើធុរកិច្ចផ្សេងទៀត ត្រូវស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតដោយឡែកសម្រាប់សកម្មភាពដោយឡែក និងត្រូវស្នើសុំអាជ្ញាបណ្ណ ឬលិខិតអនុញ្ញាតពាក់ព័ន្ធផ្សេងៗ ស្របតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ៣.-**

អ្នកទទួលបានអាជ្ញាបណ្ណត្រូវស្នើសុំ និងទទួលបានអាជ្ញាបណ្ណនិង/ឬលិខិតអនុញ្ញាតផ្សេងៗពីស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ស្របតាមការតម្រូវនៃច្បាប់ជាធរមាន ដើម្បីអនុវត្តកាតព្វកិច្ចនានា ដូចមានចែងក្នុងអាជ្ញាបណ្ណនេះ។

**ប្រការ៤ .-**

ប្រកាសនេះមានរយៈពេលសុពលភាព ស្របតាមរយៈពេលសុពលភាពនៃអាជ្ញាបណ្ណសន្និធិឧស្ម័នអិល ភី ជី លេខ..០០០៥ [illegible]... ចុះថ្ងៃទី.....០១..ខែ..មេសា....ឆ្នាំ..២០១២. និងអាចពន្យារបន្តបានស្របតាមអាជ្ញាបណ្ណនេះ និងបទប្បញ្ញត្តិជាធរមាន។

**ប្រការ ៥.-**

ក្រុមហ៊ុនត្រូវបំពេញកាតព្វកិច្ចរបស់ខ្លួនដូចតទៅ៖

**១. កាតព្វកិច្ចគោរពច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត**

១.១ ក្រុមហ៊ុនត្រូវធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាពរបស់ក្រសួងរ៉ែនិងថាមពលក្នុងការសាងសង់មណ្ឌលសន្និធិឧស្ម័នអិល ភី ជី របស់ខ្លួន។ ក្នុងករណីមិនទាន់មានបទដ្ឋានរបស់ក្រសួងរ៉ែនិងថាមពល ក្រុមហ៊ុនត្រូវធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសសុវត្ថិភាពដែលជាទម្លាប់អនុវត្តល្អបំផុតជាអន្តរជាតិ ក្នុងការសាងសង់មណ្ឌលសន្និធិឧស្ម័នអិល ភី ជី។

១.២ ក្រុមហ៊ុនត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងនីតិវិធីនានា ដែលក្រសួងរ៉ែនិងថាមពលសម្រេចដាក់ឱ្យអនុវត្តសម្រាប់កិច្ចដំណើរការសាងសង់ និងធ្វើប្រតិបត្តិការមណ្ឌលសន្និធិឧស្ម័នអិល ភី ជី។

១.៣ ក្រុមហ៊ុនត្រូវគោរពតាមកាតព្វកិច្ចបរិស្ថានដែលបានកំណត់ក្នុងច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ របស់ព្រះរាជាណាចក្រកម្ពុជា។

១.៤ ក្រុមហ៊ុនត្រូវគោរព និងអនុវត្តតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាននានារបស់ព្រះរាជាណាចក្រកម្ពុជា។

**២. កាតព្វកិច្ចក្នុងការរៀបចំមណ្ឌលសន្និធិឧស្ម័នអិល ភី ជី**

២.១ ក្រុមហ៊ុនត្រូវធ្វើការរៀបចំមណ្ឌលសន្និធិឧស្ម័នអិល ភី ជី នៅលើទីតាំងដែលបានកំណត់។

២.២ ក្រុមហ៊ុនត្រូវធ្វើការរៀបចំមណ្ឌលសន្និធិឧស្ម័នអិល ភី ជី តាមផែនការ គំនូសប្លង់ស្ថាបត្យកម្ម និងប្លង់គ្រឿងបង្គុំសំណង់ ដែលមានការយល់ព្រមពីក្រសួងរ៉ែនិងថាមពល។ ក្នុងករណីមានការកែប្រែផែនការ គំនូសប្លង់ផ្សេងៗ ក្រុមហ៊ុនត្រូវស្នើសុំការយល់ព្រមពីក្រសួងរ៉ែនិងថាមពល មុនចាប់ផ្តើមការរៀបចំ។

២.៣ ក្រុមហ៊ុនត្រូវរាយការណ៍មកអគ្គនាយកដ្ឋានប្រេងកាត ឱ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន អំពីហានិភ័យផ្សេងៗ ដែលប៉ះពាល់ធ្ងន់ធ្ងរដល់ដំណើរការរៀបចំមណ្ឌលសន្និធិឧស្ម័នអិល ភី ជី របស់ខ្លួន។

២.៤ ក្រុមហ៊ុនត្រូវផ្តល់នូវរបាយការណ៍អំពីវឌ្ឍនភាពក្នុងការរៀបចំមណ្ឌលសន្និធិឧស្ម័នអិល ភី ជី នេះជាប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១ នៃត្រីមាសបន្ទាប់។

២.៥ ក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ឧបទ្ទវហេតុនិងគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងអំឡុងពេលដំណើរការមណ្ឌលសន្និធិឧស្ម័នអិល ភី ជីរបស់ខ្លួន។

២.៦ ក្រុមហ៊ុនមិនត្រូវប្រគល់ ឬផ្ទេរសិទ្ធិបង្កើតមណ្ឌលសន្និធិនេះឱ្យអ្នកដទៃដោយគ្មានការអនុញ្ញាត ពីក្រសួងរ៉ែនិងថាមពល ឡើយ។

**៣. កាតព្វកិច្ចផ្សេងទៀត**

៣.១ ក្រុមហ៊ុនត្រូវផ្តល់ប្លង់បច្ចេកទេសជាក់ស្តែងនៃសំណង់មណ្ឌលសន្និធិឧស្ម័នអិល ភី ជី ក្រោយសាងសង់រួចជាស្ថាពរ មួយច្បាប់ សម្រាប់តម្កល់នៅអគ្គនាយកដ្ឋានប្រេងកាត។

៣.២ ក្រុមហ៊ុនត្រូវផ្តល់ឱ្យបានត្រឹមត្រូវនូវទិន្នន័យឧស្ម័នអិល ភី ជី ដែលបាននាំចូល និងលក់ចែកចាយជាប្រចាំត្រីមាស នៅក្នុងសប្តាហ៍ទី១នៃត្រីមាសបន្ទាប់ និងប្រចាំឆ្នាំ នៅសប្តាហ៍ទី១នៃឆ្នាំបន្ទាប់ មកក្រសួងរ៉ែនិងថាមពល។

៣.៣ ក្រុមហ៊ុនត្រូវទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់នូវរាល់ឧបទ្ទវហេតុនិងគ្រោះថ្នាក់ទាំងឡាយ ដែលកើតឡើងក្នុងអំឡុងពេលប្រតិបត្តិការមណ្ឌលសន្និធិឧស្ម័នអិល ភី ជីរបស់ខ្លួន។

៣.៤ ក្រុមហ៊ុនត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ក្រសួងរ៉ែនិងថាមពល ក្នុងគោលបំណងអនុវត្តការចុះធ្វើអធិការកិច្ចដើម្បីឱ្យការគ្រប់គ្រងមណ្ឌលសន្និធិឧស្ម័នអិល ភី ជី មានប្រសិទ្ធភាពខ្ពស់។

**ប្រការ៦.-**

មុនដំណើរការមណ្ឌលសន្និធិឧស្ម័នអិល ភី ជី នេះ រយៈពេល ៩០ (កៅសិប) ថ្ងៃ ក្រុមហ៊ុនត្រូវជូនដំណឹង និងដាក់ពាក្យស្នើសុំ **លិខិតអនុញ្ញាតដំណើរការមណ្ឌលសន្និធិឧស្ម័នអិល ភី ជី** ពីក្រសួងរ៉ែនិងថាមពល។

**ប្រការ៧.-**

អាជ្ញាបណ្ណនេះនឹងត្រូវដកហូតដោយគ្មានលក្ខខណ្ឌ ប្រសិនបើក្រុមហ៊ុនមិនបានចាប់ផ្តើមសាងសង់មណ្ឌលសន្និធិឧស្ម័នអិល ភី ជី នេះ ក្នុងរយៈពេល១២ (ដប់ពីរ) ខែ ចាប់ពីកាលបរិច្ឆេទនៃប្រកាសនេះ ឬ ក្រុមហ៊ុនបានប្រព្រឹត្តល្មើសច្បាប់ ឬល្មើសធ្ងន់ធ្ងរនឹងលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងប្រកាសនេះ។

**ប្រការ៨.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានប្រេងកាតអគ្គាធិការ ប្រធាននាយកដ្ឋានពាក់ព័ន្ធ ប្រធានមន្ទីររ៉ែនិងថាមពលខេត្តបន្ទាយមានជ័យ និងប្រធានក្រុមហ៊ុន **ឡែក សូណាល់ ស៊ីវីស** ត្រូវអនុវត្តប្រកាសនេះ តាមភារកិច្ចទទួលបន្ទុករៀងៗខ្លួនឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សៅរ៍ ១កើត ខែ ចេត្រ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០២២

**រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល**

**ស៊ុយ សែម**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចឯកឧត្តមលោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តបន្ទាយមានជ័យ
- ដូចប្រការ ៨
- រាជកិច្ច
- ឯកសារកាលប្បវត្តិ